អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៦/០១/២០១១ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀតស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០៩/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះមានគោលដៅ បង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុងកំពង់ត្រាច ខេត្តកំពត ។

មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណង ៖

- ការពារ និងអភិរក្សធនធានសេនេទិចសត្វព្រៃ មច្ឆជាតិ និងរុក្ខជាតិ ពិសេសសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ដែលបានប្រភេទជិតផុតពូជ ប្រភេទមានដោយកម្រ ប្រភេទកំពុងទទួលរងគ្រោះថ្នាក់ និងរក្សាលំនឹង មជ្ឈដ្ឋានធម្មជាតិ និងទីជម្រករបស់វា
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល អភិវឌ្ឍន៍សហគមន៍ និងការអង្កេតតាមដានពីភាពប្រែប្រួលបរិស្ថាន

ដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- ការពារប្រភពចំណី និងថែរក្សាប្រភពទឹក ឱ្យមានប្រក្រតីភាពសម្រាប់ជីវៈចម្រុះដើម្បីធានាឱ្យមាននិរន្តរភាព ប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ចសង្គម និងបរិស្ថាន
- ទប់ស្កាត់រាល់ការចូលរុករានទន្ទ្រានកាប់បំផ្លិចបំផ្លាញធនធានធម្មជាតិ ពិសេសការរំលោភយកដីធ្វើកម្មសិទ្ធិ ធ្វើស្រែបង្ការ និងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀត
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាជម្រកសម្រាប់ការស្នាក់អាស្រ័យសុខសាន្ត និងការបន្តពូជរបស់សត្វព្រៃ មច្ឆជាតិ និងរុក្ខជាតិ
- បម្រើឱ្យគោលដៅអេកូទេសចរណ៍ ។

## ជំពូកទី២
## ការកំណត់តំបន់

មាត្រា៣ .-

តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀតដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ មានផ្ទៃក្រឡា ទំហំ ២១៧ (ពីររយដប់ប្រាំពីរ) ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមការ ៖

0(448534,1159354); 1(448141,1158984); 2(448049,1158828); 3(447989,1158678); 4(448464,1158909); 5(448652,1158977); 6(448735,1159127); 7(448022,1158637); 8(447986,1158493); 9(447784,1158527); 10(447708,1158585); 11(447696,1158681); 12(447570,1158694); 13(447586,1158585); 14(447644,1158505); 15(447735,1158475); 16(447825,1158457); 17(447830,1158389); 18(447847,1158323); 19(447879,1158315); 20(447862,1158138); 21(447876,1158098); 22(447670,1157480); 23(447661,1157345); 24(447692,1157252); 25(447757,1157164); 26(448312,1156868); 27(448536,1156797); 28(448861,1156725); 29(448884,1156374); 30(448826,1156142); 31(448961,1155815); 32(448977,1155963); 33(449010,1155881); 34(449051,1155873); 35(449070,1156522); 36(449111,1155939); 37(449490,1156316); 38(449502,1156360); 39(449450,1156522); 40(449371,1156694); 41(449327,1156767); 42(449212,1156915); 43(449161,1156955); 44(449082,1156999); 45(449045,1157005); 46(448993,1156984); 47(448748,1157464); 48(448673,1157568); 49(448575,1157440); 50(448590,1157424); 51(448502,1157323); 52(448469,1157346); 53(448442,1157312); 54(448327,1157369); 55(448229,1157469); 56(448229,1157469); 57(448187,1157331); 58(448197,1157580); 59(448226,1157491); 60(448268,1157718); 61(448187,1157589); 62(448291,1157646); 63(448591,1157679); 64(448286,1157718); 65(448472,1158082); 66(448498,1157573); 67(448591,1157681); 68(448467,1158082); 69(448528,1158172); 70(448446,1158303); 71(448431,1158409); 72(448440,1158478) ។

មាត្រា៤.~

ផ្ទៃក្រឡាតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ដូចមានចែងក្នុងមាត្រា៣ ខាងលើនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនាពេលអនាគត ។

## ជំពូកទី៣

## ការគ្រប់គ្រង

មាត្រា៥.~

តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំង អន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត ត្រូវបានការពារ និងអភិរក្សយ៉ាងហ្មត់ចត់បំផុតដើម្បីធានាឱ្យបានគង់វង្សនូវទីជម្រក និងប្រភពចំណីអាហារសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ។

តំបន់នេះអាចអនុញ្ញាតឱ្យមានសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រ ការអង្កេតតាមដាន បម្រើឱ្យគោលដៅអេកូទេសចរណ៍ និងការនេសាទប្រកបដោយនិរន្តរភាព ដោយមិនអនុញ្ញាតឱ្យមានសកម្មភាពប្រើប្រាស់ដែលធ្វើឱ្យរេចរឹល ឬបំផ្លិចបំផ្លាញដល់ជីវៈចម្រុះឡើយ ។

មាត្រា៦.~

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពក ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងរដ្ឋបាលដែនដី ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ដំណើរការនៃការរៀបចំ និងការគ្រប់គ្រងតំបន់គ្រប់គ្រង និង អភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

មាត្រា៧.~

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៨.~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។